រ៉ូស៊ី មានអារម្មណ៍នឿយហត់ដែលមានអារម្មណ៍
ដូចជាមិនចុះចំណោមនឹងគេ ។



# ការអធិដ្ឋានរបស់ រ៉ូស៊ី

ដោយ លូស៊ី ស្ទីវិនសុន អ៊ីវេល
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅ ស.រ.អា. ។*

រ៉ូស៊ី បានទម្លាក់កាបូបស្ពាយរបស់នាងនៅលើឥដ្ឋ ។ នាងទើបតែរៀនបានថ្ងៃទីពីរនៅថ្នាក់ថ្មីរបស់នាង ។ ហើយវាមិនមែនជាថ្ងៃល្អទេ ។

« មានរឿងអី ?» ម៉ាក់បានសួរ ។

រ៉ូស៊ី បានទម្លាក់ខ្លួននៅលើសាឡុង ។ នាងបាននិយាយថា « ក្មេងៗខ្លះនៅថ្នាក់របស់នាងនិយាយមិនល្អចំពោះខ្ញុំ » ។ « អំពីសម្បុរពណ៌លឿងរបស់ខ្ញុំ » ។

ក្មេងជាច្រើននៅសាលារបស់នាងមិនមានសម្បុរដូច រ៉ូស៊ី ឡើយដូច្នេះហើយនាងមានអារម្មណ៍មិនចុះចំណោមនឹងគេទេ ។ ប៉ុន្តែការលេងសើចបាន ធ្វើឲ្យនាងមានអារម្មណ៍មិនល្អរាប់រយដង ។

ម៉ាក់មើលទៅបារម្ភណាស់ ។ គាត់បាននិយាយថា « ម៉ាក់សោកស្ដាយណាស់ » ។ គាត់បានឱប រ៉ូស៊ី ។ « ម៉ាក់នឹងនិយាយជាមួយគ្រូរបស់កូនអំពីរឿងនេះ » ។

ប៉ុន្តែនៅថ្ងៃបន្ទាប់នៅសាលា រ៉ូស៊ី រងនូវការលេងសើចម្ដងទៀត ។ ក្មេងប្រុសម្នាក់នៅក្នុងថ្នាក់របស់នាង និយាយមិនល្អចំពោះនាងពេញមួយថ្ងៃ ។

រ៉ូស៊ី មានអារម្មណ៍មិនល្អទេ ។ ហើយនាងក៏មានអារម្មណ៍ខឹងណាស់ដែរ ។ ពេលខ្លះនៅពេលគាត់ឈ្លើយដាក់នាង រ៉ូស៊ី បានប្រកែកតបវិញ ។ ប៉ុន្តែវាមិនធ្វើឲ្យនាងមានអារម្មណ៍ល្អ នោះទេ ។

នៅថ្ងៃមួយនៅពេល រ៉ូស៊ី បានមកដល់ផ្ទះពីសាលា នាងរត់តម្រង់ទៅបន្ទប់របស់នាង ។ នាងធុញថប់នឹងការលេងសើចនោះណាស់ ។ នាងនឿយហត់ចំពោះ ការមានអារម្មណ៍ថាមិនចុះចំណោម ។ នាងបានផ្កាប់មុខលើខ្នើយ ហើយយំ ។

*នាងបានគិតថា* តើខ្ញុំនឹងធ្វើអ្វីទៅ ? នាងមិនចង់មានអារម្មណ៍ដូចនេះពេញមួយឆ្នាំសិក្សានេះទេ ។

រ៉ូស៊ី បានជូតទឹកភ្នែករបស់នាង ។ បន្ទាប់មក នាងងើយមើលលើរូបសំណាកដ៏តូចរបស់ព្រះយេស៊ូវនៅលើធ្នើររបស់នាង ។ ម៉ាក់បានឲ្យវាទៅរ៉ូស៊ី ដើម្បីជួយនាងចងចាំពីព្រះយេស៊ូវ ។

*នាងបានគិតថា* ប្រហែលជាខ្ញុំត្រូវអធិស្ឋាន ។ នាងបានលុតជង្គង់ចុះ ហើយបានឱបដៃ ។

« ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ ខ្ញុំម្ចាស់ពិតជាឈឺចាប់ក្នុងចិត្តណាស់ ។ មិត្តរួមថ្នាក់របស់ខ្ញុំម្ចាស់បានធ្វើមិនល្អដាក់ខ្ញុំម្ចាស់ ពីព្រោះខ្ញុំមានសម្បុរពណ៌លឿង ហើយធ្វើឲ្យខ្ញុំមានអារម្មណ៍មិនល្អ ។ សូមជួយខ្ញុំម្ចាស់ផង ។

វាមានអារម្មណ៍ល្អណាស់ដើម្បីទូលប្រាប់ពីអារម្មណ៍របស់នាងទៅកាន់ព្រះវរបិតាសួគ៌ ។ នាងដឹងថាទ្រង់ស្ដាប់ ។ នាងមានអារម្មណ៍កក់ក្ដៅ និងទទួលក្ដីស្រឡាញ់ ដូចជាភួយដ៏ទន់មករុំជុំវិញនាង ។ នាងមានអារម្មណ៍ដូចជាពណ៌សម្បុររបស់នាងស្រស់ស្អាតណាស់ ។ នាងជាបុត្រីរបស់ព្រះ ហើយទ្រង់ស្រឡាញ់នាង ។

នៅពេល រ៉ូស៊ី បានអធិស្ឋានចប់ នាងមានគំនិតមួយ ។ ប្រហែលជាមានអ្វីច្រើនដែលនាងអាចធ្វើដើម្បីជួយសាលានាង ។

នៅសប្ដាហ៍ក្រោយ រ៉ូស៊ី និងម៉ាក់របស់នាងបានជួបជាមួយអ្នកគ្រប់គ្រងនៅសាលាទាក់ទងនឹងអ្វីដែលកំពុងកើតឡើងនៅក្នុងថ្នាក់របស់នាង ។ រ៉ូស៊ី បានរកមើលក្មេងនៅសាលាដែលបានធ្វើបាបនាង ហើយបានធ្វើជាមិត្តនឹងពួកគេ ។ នាងព្យាយាមមិនខ្វល់ខ្វាយពីក្មេងប្រុសដែលលេងសើចនឹងនាង ហើយនៅព្រះវិហារនៅថ្ងៃអាទិត្យ នាងបានចែកចាយទីបន្ទាល់ថា ព្រះវរបិតាសួគ៌ស្រឡាញ់*មនុស្សគ្រប់គ្នា* ។

អ្វីៗនៅសាលាមិនល្អប្រសើរភ្លាមៗនោះទេ ។ ប៉ុន្តែនៅពេលវាពិបាក រ៉ូស៊ី នឹកឃើញពីរបៀបដែលនាងទទួលអារម្មណ៍អំឡុងការអធិស្ឋានរបស់នាង ។ នាងគឺជាបុត្រីរបស់ព្រះ ហើយនាងទទួលបានក្ដីស្រឡាញ់នោះ ។ ហើយដោយសារនាងបានដឹងពីរឿងនោះ នាងអាចធ្វើអ្វី គ្រប់យ៉ាង ។ ●





## គន្លឹះរបស់ រ៉ូស៊ីដើម្បី ដោះស្រាយពីការរើសអើងពូជសាសន៍

**ការរើសអើងពូជសាសន៍** គឺនៅពេលមនុស្សទទួលរងអំពើដោយអយុត្តិធម៌ ដោយសារតែពណ៌សម្បុរ ឬជីវប្រវត្តិរបស់ពួកគេ ។ នេះជាអ្វីដែលអ្នកអាចធ្វើ ៖

- សូមចងចាំថា អ្នកគឺជាបុត្ររបស់ព្រះ ។
- ប្រព្រឹត្តិចំពោះមនុស្សគ្រប់គ្នាដោយក្ដីស្រឡាញ់សប្បុរស និងដោយការគោរព ។ សូមចងចាំថាពួកគេក៏ជាបុត្រាបុត្រីរបស់ព្រះដែរ ។
- ប្រសិនបើអ្នកធ្វើបាប ឬបើប្អូនឃើញនរណាម្នាក់ទទួលរងការធ្វើបាប សូមប្រាប់ទៅមជ្ឈិមវ័យ ។ ក្រោកឈរការពារខ្លួនរបស់អ្នក ប៉ុន្តែសូមកុំធ្វើទង្វើមិនល្អដូចដែលគេបានធ្វើចំពោះអ្នកឡើយ ។
- សូមចែកចាយបទពិសោធន៍របស់អ្នកជាមួយនឹងអ្នកដទៃ ។ សូមជួយពួកគេឲ្យដឹងថា ពួកគេមិននៅ ឯកោនោះទេ ។
- ក្រោកឈរការពារអ្នកដទៃ ដែលបានទទួលរងអំពើអយុត្តិធម៌ ។ ធ្វើជាមិត្តនឹងពួកគេ ។